# លិខិតបទដ្ឋានគតិយុត្ត

*ដោយៈ បណ្ឌិត* **ហែម ឡាច** *មន្ត្រីនាយកដ្ឋាននីតិសាស្ត្រ*
*វិទ្យាស្ថានមនុសាស្ត្រនិងវិទ្យាសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*លិខិតបទដ្ឋានគតិយុត្ត គឺជាវិធានច្បាប់ ឬវិធានគតិយុត្តទាំងឡាយណាដែលចេញដោយស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចតាមលំដាប់ថ្នាក់ដើម្បីដឹកនាំ គ្រប់គ្រងទំនាក់ទំនងរបស់មនុស្សក្នុងសង្គម គ្រប់វិស័យឱ្យមានរបៀបរៀបរយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុខមាលភាព ការអភិវឌ្ឍ និងភាពសុខសាន្តក្នុងសង្គមជាតិ។*

*លិខិតបទដ្ឋានគតិយុត្ត មានតាមលំដាប់ដូចជា រដ្ឋធម្មនុញ្ញ សន្ធិសញ្ញា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងដីកា។*

*វិធានគតិយុត្ត ទាំងនេះគឺជាវិធានច្បាប់ដែលបង្កើតនូវសិទ្ធិ និងកាតព្វកិច្ចចំពោះប្រជាពលរដ្ឋ និងមន្ត្រីរាជការ ហើយមានទណ្ឌកម្មចំពោះជនដែលប្រព្រឹត្តខុស។*

*វិធានខ្លះមិនមែនជាវិធានគតិយុត្តទេ ដូចជាវិធានសីលធម៌ វិធានសាសនា ឬវិធានសុជីវធម៌ ជាដើម។ វិធានទាំងនេះមិនបង្កើតនូវសិទ្ធិ ឬកាតព្វកិច្ចអ្វីខាងផ្លូវច្បាប់ដល់បុគ្គលណាមួយឡើយ បើសិនជាអ្នកណាមិនគោរព អ្នកនោះក៏គ្មានទោសពៃរ៍អ្វីដែរ (គឺគ្មានសំណង ពិន័យ ឬទោសព្រហ្មទណ្ឌពីអាជ្ញាធរចំពោះការមិនគោរព)។ វាទាក់ទងទៅនឹងផ្លូវចិត្ត និងជំនឿផ្ទាល់របស់បុគ្គល គឺថាមិនដូចវិធានគតិយុត្តទេ។*

*លិខិតបទដ្ឋានគតិយុត្តមានប្រភពចេញមកពីស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័ននីតិប្រតិបត្តិ។*

## ១-ប្រភពពីស្ថាប័ននីតិបញ្ញត្តិ

### ១.១-រដ្ឋធម្មនុញ្ញ

*រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ រដ្ឋធម្មនុញ្ញ ជាប្រភពដើមនៃអំណាចដែលចេញមកពីប្រជាពលរដ្ឋ។ ច្បាប់និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋត្រូវស្រេបនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។*

*ថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៤៦ មានការបោះឆ្នោតជាសកលលើកដំបូងនៅកម្ពុជា ជ្រើសតាំងសមាជិកសភាធម្មនុញ្ញ៦៧រូប ដែលមានបេសកកម្មតាក់តែងរដ្ឋធម្មនុញ្ញទី១ នៃព្រះរាជាណាចក្រកម្ពុជា ហើយព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជា ទ្រង់ប្រោសព្រះរាជទានរដ្ឋធម្មនុញ្ញ*

នេះដល់ប្រជារាស្ត្រខ្មែរនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៤៧។

រដ្ឋធម្មនុញ្ញបច្ចុប្បន្ន ត្រូវបានអនុម័ត ដោយសភាធម្មនុញ្ញ នៅថ្ងៃអង្គារ ៦កើត ខែកទ្រុបទ ឆ្នាំរកា បញ្ចស័ក ព.ស.២៥៣៧ ត្រូវនឹងថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ហើយត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមនៅថ្ងៃសុក្រ ៩កើត ខែកទ្រុបទ ឆ្នាំរកា បញ្ចស័ក ព.ស. ២៥៣៧ ត្រូវនឹងថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣។

រដ្ឋធម្មនុញ្ញនេះ មាន១៧ជំពូក និង ១៦០មាត្រា។ ជំពូកទី១ ចែងអំពីអធិបតេយ្យ ជំពូកទី២ អំពីព្រះមហាក្សត្រ ជំពូកទី៣ អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ជំពូកទី៤ អំពីរបបនយោបាយ ជំពូកទី៥ អំពីសេដ្ឋកិច្ច ជំពូកទី៦ អំពីអប់រំ វប្បធម៌ និងសង្គមកិច្ច ជំពូកទី៧ អំពីរដ្ឋសភា ជំពូកទី៨ថ្មី អំពីព្រឹទ្ធសភាជំពូកទី៩ថ្មី អំពីសមាជរដ្ឋសភា និងព្រឹទ្ធសភា ជំពូកទី១០ថ្មី អំពីរាជរដ្ឋាភិបាល ជំពូកទី១១ថ្មី អំពីអំណាចតុលាការ ជំពូកទី១២ថ្មី អំពីក្រុមប្រឹក្សាធម្មនុញ្ញ ជំពូកទី១៣ថ្មី អំពីការគ្រប់គ្រងរដ្ឋបាល ជំពូកទី១៤ថ្មី អំពីសមាជជាតិ ជំពូកទី១៥ថ្មី(ពីរ) អំពីអង្គការរៀបចំការបោះឆ្នោត ជំពូកទី១៦ថ្មី (ពីរ) អំពីអានុភាព ការសើរើនិងវិសោធនកម្មរដ្ឋធម្មនុញ្ញ និងជំពូកទី១៧ថ្មីអំពីអន្តរបញ្ញត្តិ។[1]

**១.២-សន្ធិសញ្ញា**

សន្ធិសញ្ញា (Treaty) ឬអនុសញ្ញា (Convention) ឬធម្មនុញ្ញ (Charter) ឬកតិកាសញ្ញា (Pact) ឬកិច្ចព្រមព្រៀង (Agreement/Accord) មានន័យដូចគ្នា គឺជាច្បាប់អន្តរជាតិដែលជាកិច្ចព្រមព្រៀងធ្វើឡើងរវាងរដ្ឋនិងរដ្ឋ (អាចទ្វេភាគីឬពហុភាគី) ក្នុងទង្វើជាលាយលក្ខណ៍អក្សរសម្រាប់គ្រប់គ្រងទំនាក់ទំនងអន្តរជាតិ និងដោះស្រាយបញ្ហារវាងប្រទេសនានាក្នុងពិភពលោក។ ប៉ុន្តែការប្រើពាក្យនីមួយៗ អាស្រ័យនឹងប្រភេទនៃវិស័យនីមួយៗ ឬបរិបទ ឬតាមតំបន់ពុំមានពាក្យណាធំជាងឬតូចជាងពាក្យណាទេ។

**ឧទាហរណ៍៖**

-ធម្មនុញ្ញអង្គការសហប្រជាជាតិ ធម្មនុញ្ញសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍

-កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឬស្តីពីសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌

-អនុសញ្ញា ស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍

-សន្ធិសញ្ញា ស្តីពីតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ

-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលកូរ៉េខាងត្បូង ស្តីពីការជំរុញ និងការការពារ វិនិយោគ។ល។

[1] អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ៖ *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣*

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី មាត្រា១២ បានចែង "នាយករដ្ឋមន្ត្រីដឹកនាំ ការចរចា និងចុះហត្ថលេខាពល់កិច្ចព្រមព្រៀងពាណិជ្ជកម្ម សហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្របច្ចេកទេស និងការពារប្រទេស។ នាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិឱ្យសមាជិករាជរដ្ឋាភិបាលណាម្នាក់ ជាអ្នកចរចា និងជាអ្នកចុះហត្ថលេខា។

មាត្រា២៦ថ្មី នៃរដ្ឋធម្មនុញ្ញចែងថា "ព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា"។

**១.៣-ច្បាប់**

ច្បាប់ គឺជាវិធានសរសេរមានលក្ខណៈទូទៅ និងអចិន្ត្រៃយ៍ ដែលផ្តួចផ្តើមដោយសមាជិកសភា (សេចក្តីស្នើច្បាប់) ឬដោយរាជរដ្ឋាភិបាល (សេចក្តីព្រាងច្បាប់) ហើយត្រូវបានអនុម័តដោយសភា បន្ទាប់មកត្រូវប្រកាសឱ្យប្រើដោយព្រះមហាក្សត្រតាមរយៈព្រះរាជក្រម។

ច្បាប់មានលក្ខណៈទូទៅ ដាច់ខាត អចិន្ត្រៃយ៍ និងមានទណ្ឌកម្មដែលត្រូវអនុវត្តដោយអាជ្ញាធរ សាធារណៈ។

**-លក្ខណៈទូទៅ ដាច់ខាត៖** គឺអនុវត្តទៅលើជនគ្រប់រូបទូទៅ និងគ្រប់ទីកន្លែងទូទាំងប្រទេសដូចៗគ្នា មិនរើសអើង ទោះជាអ្នកមាន ឬអ្នកក្រ មន្ត្រី ឬរាស្ត្រ។

**-លក្ខណៈអចិន្ត្រៃយ៍៖** មានន័យថា ពេលដែលវានៅជាធរមានត្រូវអនុវត្តជារហូតលុះត្រាមានការធ្វើវិសោធនកម្ម ឬមានច្បាប់ថ្មីមកជំនួស។

**-មានទណ្ឌកម្ម៖** ចំពោះជនដែលបំពាន មិនគោរព ឬរំលោភច្បាប់ គឺត្រូវតែដាក់ទណ្ឌកម្មចំពោះជននោះដែលអាចជាសំណង ពិន័យ ឬនិងទោសព្រហ្មទណ្ឌ(ដាប់ពន្ធនាគារ)។

**•ព្រះរាជក្រម៖**

ព្រះរាជក្រម គឺជាលិខិតបទដ្ឋានមួយដែលឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ សម្រាប់ប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ និងច្បាប់នានា ដែលអនុម័តដោយអង្គការនីតិបញ្ញត្តិ។

**ឧទាហរណ៍៖**

-ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

-ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ប្រកាសប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ។

-ព្រះរាជក្រមលេខ នស/រកម/១០២៣/០១៨ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣ ប្រកាសប្រើច្បាប់ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

## ២-ប្រភពពីស្ថាប័ននីតិប្រតិបត្តិ

### ២.១-ព្រះរាជក្រឹត្យ

*ព្រះរាជក្រឹត្យ គឺជាលិខិតបទដ្ឋានមួយដែលឡាយព្រះហស្ដលេខាដោយព្រះមហាក្សត្រតាមសេចក្ដីស្នើសុំពីគណៈរដ្ឋមន្ត្រី (នាយករដ្ឋមន្ត្រី) ឬតាមព្រះរាជសិទ្ធិរបស់ព្រះមហាក្សត្រ។ ព្រះរាជក្រឹត្យមានទម្រង់ជាៈ*

***ក-ព្រះរាជក្រឹត្យបទបញ្ជាៈ*** *ច្បាប់បានកំណត់នូវកិច្ចការឬវិស័យមួយចំនួនរបស់ប្រទេសជាតិ ថាត្រូវធ្វើជាព្រះរាជក្រឹត្យដើម្បីជាលិខិតបទដ្ឋាន(បទបញ្ជា)បន្តសម្រាប់អនុវត្តច្បាប់(ពីព្រោះច្បាប់គ្រាន់តែចែងចំណុចគោលៗដោយទុកឱ្យរដ្ឋាភិបាលរៀបចំធ្វើជាព្រះរាជក្រឹត្យចែងលម្អិតនូវខ្លឹមសារបន្ត) សម្រាប់មន្ត្រី ឬប្រជាពលរដ្ឋយកទៅគោរពអនុវត្ត។*

***ឧទាហរណ៍ៈ***

*-ព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៣៨២ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨ ស្ដីពីការប្ដូរក្រុងប៉ៃលិន ទៅជា ខេត្តប៉ៃលិន។*

*-ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្ដីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ។*

*-ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១២៤៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការបង្កើតខេត្តត្បូងឃ្មុំ។*

*-ព្រះរាជក្រឹត្យលេខ នស/រកត/១២១៩/១៩៦២ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។*

*-ព្រះរាជក្រឹត្យលេខ នស/រកត/០៣២៣/៤២០ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា។*

*មាត្រា៧ វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញចែងថា "ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជ្យសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ"។ ដូច្នេះ ព្រះអង្គពុំអាចចេញសេចក្ដីសម្រេចជាបទបញ្ជាបានឡើយ។ រាល់សេចក្ដីសម្រេចធ្វើបទបញ្ជា ជាភារកិច្ចរបស់រាជរដ្ឋាភិបាល។ ព្រះមហាក្សត្រជាអ្នកផ្ដល់នីត្យានុកូលភាពដល់រាល់បទបញ្ជាដែលសម្រេចឡើងដោយគណៈរដ្ឋមន្ត្រី(គឺផ្ដល់នូវភាពស្របច្បាប់ដល់ព្រះរាជក្រឹត្យ ពីព្រោះរដ្ឋធម្មនុញ្ញបានចែងថាព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ដលេខាលើព្រះរាជក្រឹត្យតាមសេចក្ដីស្នើរបស់គណៈរដ្ឋមន្ត្រី)។*

***ខ-ព្រះរាជក្រឹត្យឯកត្តភូតៈ*** *ព្រះរាជក្រឹត្យឯកត្តភូតមានពីរបែប គឺព្រះរាជក្រឹត្យចាត់តាំង និង ព្រះរាជក្រឹត្យតែងតាំង។*

*-តាមសេចក្ដីស្នើពីប្រធានដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា*

ព្រះមហាក្សត្រ ទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែល ឈ្នះឆ្នោត ឱ្យបង្កើតរាជរដ្ឋាភិបាល(មាត្រា ១១៩ថ្មីនៃរដ្ឋធម្មនុញ្ញ)។

-សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវ បានចាត់តាំងដោយព្រះមហាក្សត្រ (មាត្រា ១០០ថ្មី)។

-ព្រះមហាក្សត្រ ទ្រង់តែងតាំងនាយក រដ្ឋមន្ត្រី និង ទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី តាម បែបបទដែលមានចែងក្នុងមាត្រា១១៩ថ្មី។

-នាយករដ្ឋមន្ត្រី លើកសំណើថ្វាយ ព្រះមហាក្សត្រតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ច ដោយព្រះរាជក្រឹត្យចំពោះអគ្គទេសាភិបាល អគ្គទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ទី ប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សានាយករដ្ឋមន្ត្រី អគ្គលេខាធិការ អគ្គនាយក អគ្គាធិការក្រសួង សាកលវិទ្យាធិការ ប្រតិភូរាជរដ្ឋាភិបាល អភិបាលរាជធានី ខេត្ត ឯកអគ្គរាជទូត ប្រេសិតវិសាមញ្ញនិងពេញសមត្ថភាព អគ្គមេ បញ្ជាការ អគ្គមេបញ្ជាការរងនៃកងយោធពល ខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ ព្រម ទាំងមុខតំណែងប្រហាក់ប្រហែលមួយចំនួន ទៀត។

-តាមសេចក្តីស្នើរបស់ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ព្រះមហាក្សត្រទ្រង់ឡាយព្រះ ហស្តលេខាលើព្រះរាជក្រឹត្យ តែងតាំង ផ្លាស់ ប្តូរ ឬដកចៅក្រមផ្នែកយុត្តាធិការ។

**ឧទាហរណ៍៖**

-ព្រះរាជក្រឹត្យលេខ នស/រកត/ ០៨២៣/១៧៧២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០២៣ ស្តីពីការចាត់តាំងឯកឧត្តមបណ្ឌិត **ហ៊ុន ម៉ាណែត** ជា នាយករដ្ឋមន្ត្រី នៃព្រះរាជា ណាចក្រកម្ពុជា សម្រាប់នីតិកាលទី៧ នៃរដ្ឋ សភា។

-ព្រះរាជក្រឹត្យលេខ នស/រកត/ ០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា សម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា។

-ព្រះរាជក្រឹត្យលេខ នស/រកត/ ១០២៣/២២៣៩ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ ២០២៣ ស្តីពីការតែងតាំង ឯកឧត្តម **ជីវ កេង** ជាប្រធានតុលាការកំពូល នៃព្រះរាជាណា ចក្រកម្ពុជា។

-ព្រះរាជក្រឹត្យលេខ នស/រកត/ ០៧២៣/១៦៧៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០២៣ ស្តីពីការតែងតាំង លោកជំទាវ **ជា សិរី** ជាអគ្គទេសាភិបាលធនាគារជាតិនៃ កម្ពុជា។

-ព្រះរាជក្រឹត្យលេខ នស/រកត/ ០៨២៣/២០២១ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងឯកឧត្តមនាយឧត្តម សេនីយ៍ **ស ថេត** ជា អគ្គស្នងការ នៃអគ្គស្នង ការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ។

-ព្រះរាជក្រឹត្យលេខ នស/រកត/ ១១២៣/២៣៩០ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ

២០២៣ ស្តីពីការ តែងតាំងឧត្តមសេនីយ៍ឯក **ដោក សុផា** ជា សាកលវិទ្យាធិការ សាកលវិទ្យាល័យការពារជាតិ។

តាមធម្មតា ព្រះរាជក្រឹត្យត្រូវមានការស្នើសុំពីគណៈរដ្ឋមន្ត្រី ប៉ុន្តែ ព្រះរាជក្រឹត្យខ្លះពុំមានការស្នើសុំពីគណៈរដ្ឋមន្ត្រីទេ ដូចជាព្រះរាជក្រឹត្យតែងតាំងសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ ព្រះរាជក្រឹត្យតែងតាំងគោរមងារ និងឋានៈក្នុងព្រះរាជវង្សានុវង្ស ព្រះរាជក្រឹត្យតែងតាំងសមាជិកនៃព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ព្រះរាជក្រឹត្យតែងតាំងគោរមងារឥស្សរជនដែលជាព្រះរាជបុព្វសិទ្ធិ អនុញ្ញាតឱ្យព្រះមហាក្សត្រចេញព្រះរាជក្រឹត្យប្រភេទនេះតាមបវេណីព្រះមហាក្សត្រ។

**ឧទាហរណ៍៖**

-ព្រះរាជក្រឹត្យលេខ នស/រកត/០៣២៣/៤៨២ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ ស្តីពីការប្រគេនគោរមងារ ព្រះអរិយមុនី **កែវ ឌីម៉ង់** សមាជិកគណៈសង្ឃនាយកនៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះរាជលេខាធិការផ្ទាល់សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត **បួរ គ្រី** សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា ជា **សម្តេចព្រះពុទ្ធវ័ង្សរាជវង្សា** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/០៤២៣/៦១៤ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៣ ស្តីពីការប្រោសព្រះរាជទានគោរមងារ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ជា **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/០៥២៣/៨០៦ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២៣ ស្តីពីការតែងតាំងគោរមងារ ព្រះមហាវិមលធម្ម **ពិន សែម** ព្រះរាជាគណៈថ្នាក់ទោ ឱ្យឡើងទីជា **សម្តេចព្រះព្រហ្មរតនមុនី** គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា ។

-ព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៦៣៩ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការដំឡើងឋានៈ **ព្រះអង្គម្ចាស់ នរោត្តម ប្រិយសោភ័ណ្ឌ** ជា **ស្តេចក្រុមឃុន នរោត្តម ប្រិយសោភ័ណ្ឌ** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៣៧ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីការផ្តល់គោរមងារដល់ ឯកឧត្តមបណ្ឌិត **ស សុខា** ជា **អភិសន្តិបណ្ឌិត** នៃបណ្ឌិត្យសភានគរបាលកម្ពុជា ។

-ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១០៩ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការប្រោសព្រះរាជទានគោរមងារ **លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី** ជា **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១១០ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ

២០២៣ ស្ដីពីការប្រោសព្រះរាជទានគោរមងារ **ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត** ជា **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២២០២ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងគោរមងារ ព្រះមុនីកោសលបណ្ឌិត **យ៉ន សេងយៀត** ព្រះរាជាគណៈថ្នាក់ទោ ឱ្យឡើងទីជា **សម្ដេចព្រះមហាអរិយវង្ស** គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា ។

-ព្រះរាជក្រឹត្យលេខ នស/រកត/១១២៣/២៤៣០ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងគោរមងារ ព្រះមហាវិមលធម្ម **ហ៊ូ ឈីវនាថ** ព្រះរាជាគណៈថ្នាក់ទោ ឱ្យឡើងទីជា **សម្ដេចព្រះមង្គលមុនីវង្ស** គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា។

គោរមងារ "**សម្ដេច**" គឺជាងារដែលខ្ពស់ជាងគេបំផុតក្នុងថ្នាក់មន្ត្រីរាជការជាន់ខ្ពស់ ឬឥស្សរជននយោបាយ ដែលព្រះមហាក្សត្រអាចធ្វើព្រះរាជក្រឹត្យតែងតាំងប្រទានឱ្យយោងតាមគុណបំណាច់ដ៏ធំធេងដែលមន្ត្រីរាជការជាន់ខ្ពស់ ឬឥស្សរជននយោបាយនោះមានចំពោះប្រទេសជាតិ ចំពោះរាជបល្ល័ង្ក[2]

គោរមងារនេះក៏អាចត្រូវបានព្រះមហាក្សត្រធ្វើព្រះរាជក្រឹត្យតែងតាំងប្រទានឱ្យចំពោះព្រះសង្ឃជាន់ខ្ពស់ និងរាជវង្សានុវង្សយោងតាមគុណបំណាច់ដ៏ធំធេងផងដែរ។

គោរមងារ "**សម្ដេច**" មិនផ្ដល់សិទ្ធិដល់អ្នកទទួល ឱ្យក្លាយទៅជាស្ដេច ឬជាសមាជិកនៃព្រះរាជវង្សានុវង្សបានឡើយ។

គោរមងារ "**ឧកញ៉ា**" សំដៅដល់ងារកិត្តិយសដែលព្រះមហាក្សត្រទ្រង់ព្រះរាជទានដោយព្រះរាជក្រឹត្យ ទៅតាមលំដាប់ថ្នាក់ដល់រូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរដែលមានគុណបំណាច់ក្នុងការចូលរួមអភិវឌ្ឍនិងកសាងជាតិ។ គោរមងារ "**ឧកញ៉ា**"មាន៣លំដាប់ថ្នាក់ គឺ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និង ឧកញ៉ា។ ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិប្រោសព្រះរាជទានគោរមងារឧកញ៉ាដល់រូបវន្តបុគ្គលដែលមានគុណសម្បត្តិ គុណបំណាច់ និងមានស្នាដៃដ៏ធំធេងក្នុងបុព្វហេតុជាតិ សាសនា ព្រះមហាក្សត្រ។ នាយករដ្ឋមន្ត្រីតែម្នាក់គត់ មានសិទ្ធិលើកសំណើទូលថ្វាយព្រះមហាក្សត្រក្នុងការស្នើសុំគោរមងារឧកញ៉ានិងការបញ្ចប់គោរមងារឧកញ៉ា[3]

**ឧទាហរណ៍៖**

-ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៦/៨៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៦ ស្ដីពីការផ្ដល់គោរមងារ

**លោក យោគ រាជ** ជា **លោកអ្នកឧកញ៉ា** ។

-ព្រះរាជក្រឹត្យលេខ នស/រកត/០៩១១/៨៦៣ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១១ ស្ដីពី

[2] សាយ បូរី៖ នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៣ ភ្នំពេញ ២០០២

[3] ព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២២៥០ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ស្ដីពី គោរមងារឧកញ៉ា

*ការផ្តល់គោរមងារ* **លោកព្រឹទ្ធាចារ្យមហាឧបាសក ហ៊ុន នាង** *ជា* **អ្នកឧកញ៉ា មហាភក្តី សប្បុរិសគោត្តាធិបតី ហ៊ុន នាង** *។*

*-ព្រះរាជក្រឹត្យលេខ នស/រកត/១១១៩/១៧៩៣ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការផ្តល់គោរមងារ* **មហាឧបាសិកា ប៊ុន ស៊ាងលី** *ជា* **អ្នកឧកញ៉ា ព្រឹទ្ធមហាឧបាសិកា ធម្មញ្ញាណវិវឌ្ឍនា ប៊ុន ស៊ាងលី** *។*

*-ព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥០៩ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្តល់គោរមងារ ឯកឧត្តម* **ហ៊ុន សាន** *ជា* **អ្នកឧកញ៉ា ឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** *។*

*-ព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥១០ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្តល់គោរមងារ ឯកឧត្តម* **ត្រី ទូច** *ជា* **អ្នកឧកញ៉ា ឧត្តមមង្គលសោភ័ណត្រី ទូច** *។*

*-ព្រះរាជក្រឹត្យលេខ នស/រកត/០២២១/១៨៣ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការផ្តល់គោរមងារ ឧកញ៉ា* **គិត ម៉េង** *ជា* **អ្នកឧកញ៉ា** *។*

*-ព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៣៨៤ ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្តល់គោរមងារ ឧកញ៉ា* **ម៉ៅ ចំណាន** *ជា* **អ្នកឧកញ៉ា** *។*

*-ព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៣៨៥ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្តល់គោរមងារ លោក* **គិត ស៊ូឡា** *ជា* **ឧកញ៉ា** *។*

*-ព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២២៥៧ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣ ស្តីពីការផ្តល់គោរមងារ កញ្ញា* **ឡាយ ម៉ូនីកា** *ជា* **ឧកញ៉ា** *។*

*-ព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២២៥៨ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣ ស្តីពីការផ្តល់គោរមងារ លោកជំទាវ* **ឡាយ ឈុននី** *ជា* **ឧកញ៉ា** *។*

*ឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ ឧត្តមមន្ត្រី និងឋានន្តរស័ក្តិទី១ នៃក្របខណ្ឌប្រភេទ ក (ក១)ក៏ត្រូវដំឡើងដោយព្រះរាជក្រឹត្យផងដែរ។*

***ឧទាហរណ៍៖***

*-ព្រះរាជក្រឹត្យលេខ នស/រកត/០៣២៣/៤៥៤ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ស្តីពីការដំឡើង ឋានន្តរស័ក្តិ* **នាយឧត្តមសេនីយ៍** *ដល់ ឧត្តមសេនីយ៍ឯក* **ហ៊ុន ម៉ាណែត** *អត្តលេខ ០៣៣៨៨៣ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ។*

*-ព្រះរាជក្រឹត្យលេខ នស/រកត/០៦២៣/១០៥២ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការដំឡើងថ្នាក់និងឋានន្តរស័ក្តិក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន* **១៤៤***រូប ។*

*-ព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/៤៩៤ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០២៣ ស្ដីពីការដំឡើងឋានន្តរស័ក្តិដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ (ឧត្តមសេនីយ៍ឯក **៤**រូប និងឧត្តមសេនីយ៍ទោ **១**រូប)។*

## ២.២-អនុក្រឹត្យ

*អនុក្រឹត្យ គឺជាលិខិតបទដ្ឋាន ឬសេចក្តីសម្រេចមួយដែលចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី។ អនុក្រឹត្យ មានទម្រង់ជា៖*

***ក-អនុក្រឹត្យបទបញ្ញា៖*** *ច្បាប់បានកំណត់នូវកិច្ចការឬវិស័យណាមួយរបស់ប្រទេសជាតិ ថា ត្រូវធ្វើជាអនុក្រឹត្យដើម្បីជាលិខិតបទដ្ឋាន (បទបញ្ញា) បន្តសម្រាប់អនុវត្ត (ពីព្រោះច្បាប់គ្រាន់តែចែងចំណុចគោលៗ ដោយទុកឱ្យ ឬតម្រូវឱ្យរដ្ឋាភិបាលរៀបចំធ្វើជាអនុក្រឹត្យចែងលម្អិតនូវខ្លឹមសារបន្ត) សម្រាប់មន្ត្រី ឬប្រជាពលរដ្ឋយកទៅគោរពអនុវត្ត។*

***ឧទាហរណ៍៖***

*-អនុក្រឹត្យលេខ ១៦៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥។*

*-អនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ។*

*-អនុក្រឹត្យលេខ ២៦៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការបង្កើត **ក្រុងសំពៅពូន** នៃខេត្តកណ្តាល។*

*-អនុក្រឹត្យលេខ ២៧០ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការបង្កើត **ស្រុកអូរគ្រៀងសែនជ័យ** នៃខេត្តក្រចេះ។*

*-អនុក្រឹត្យលេខ ២៧១ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការបំបែក **ស្រុកឧដុង្គ** នៃខេត្តកំពង់ស្ពឺ។*

*-អនុក្រឹត្យលេខ ២៧២ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការបង្កើត **ក្រុងអរិយក្សត្រ** នៃខេត្តកណ្តាល។*

***ខ-អនុក្រឹត្យឯកត្តភូត៖*** *សម្រាប់តែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ច ដំឡើងឋានន្តរស័ក្តិ ថ្នាក់មន្ត្រីរាជការ នគរបាល យោធា នៅតាមក្រសួង ស្ថាប័ន និងអង្គភាពនីមួយៗរបស់រដ្ឋ។*

*នាយករដ្ឋមន្ត្រីតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ច ដោយអនុក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា ដូចជា អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង ស្រុក ខណ្ឌ អគ្គលេខាធិការរង អគ្គនាយករង អគ្គាធិការរង សាកលវិទ្យាធិការរង ព្រឹទ្ធបុរសមហាវិទ្យាល័យ ប្រធាននាយកដ្ឋាន និងមុខតំណែងផ្សេងទៀតដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ។*

***ឧទាហរណ៍៖***

*-អនុក្រឹត្យលេខ ៣៦១ អនុក្រ.តត ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣ ស្តីពីការតែងតាំងលោក* **មួង ធី** *ជាអភិបាល នៃគណៈអភិបាល* ***ស្រុកសាមគ្គីមុនីជ័យ*** *និងលោក* **ព្រាប កុយខ ឆ្លុន:** *ជាអភិបាល នៃគណៈអភិបាល* ***ក្រុងឧដុង្គម៉ែជ័យ*** *។*

*-អនុក្រឹត្យលេខ ១០៥៥ អនុក្រ.តត ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងឧត្តមសេនីយ៍ឯក* **ស រដ្ឋា** *និងឧត្តមសេនីយ៍ទោ* **ជួន ណារិន្ទ** *ជាអគ្គស្នងការរង នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ។*

*-អនុក្រឹត្យលេខ ១០៥៦ អនុក្រ.តត ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងលោក* **កៃ សួនសុភាព** *ជាអភិបាលរង នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ។*

*-អនុក្រឹត្យលេខ ១១៥១ អនុក្រ.តត ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ ស្តីពីការតែងតាំងឧត្តមនាវីទោ* **ម៉ី ឌីណា** *អត្តលេខ ០១៥១០៦ ជាមេបញ្ជាការ មូលដ្ឋានសមុទ្រ បញ្ជាការដ្ឋានកងទ័ពជើងទឹក។*

*-អនុក្រឹត្យលេខ ១២៣៥ អនុក្រ.តត ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ ស្តីពីការតែងតាំងសមាសភាពប្រតិភូនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់* **២៩***រូប មានឋានៈស្មើ* ***អគ្គនាយករង*** *។*

*-អនុក្រឹត្យលេខ ១២៦៤ អនុក្រ.តត ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការតែងតាំងឧត្តមសេនីយ៍ទោ* **ប៉ាន់ សុវណ្ណារិទ្ធ** *អត្តលេខ ៨៤៦៤០ ជាប្រធាននាយកដ្ឋាននីតិកម្ម ផែនការ និងបណ្តុះបណ្តាល នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។*

*ឋានន្តរស័ក្តិ ថ្នាក់ វរសេនីយ៍ឯក (ស័ក្តិ ៥) វរមន្ត្រី និងឋានន្តរស័ក្តិទី២ នៃក្របខណ្ឌប្រភេទ ក (ក២) ក៏ត្រូវដំឡើងដោយអនុក្រឹត្យផងដែរ។*

***ឧទាហរណ៍៖***

*-អនុក្រឹត្យលេខ ១០៦១ អនុក្រ.តត ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការដំឡើងឋានន្តរស័ក្តិ* **ថ្នាក់វរសេនីយ៍ឯក** *នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដល់ វរសេនីយ៍ទោ* **ស៊ូ កណ្ណារដ្ឋ** *អត្តលេខ ០២៨៥៣៤ មេបញ្ជាការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តសៀមរាប។*

*-អនុក្រឹត្យលេខ ៦១៣ អនុក្រ.តត ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ ស្តីពីការដំឡើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ ចំនួន ១៣៦រូប នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល។*

*-អនុក្រឹត្យលេខ ៩៤០ អនុក្រ.តត ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការដំឡើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ ចំនួន* **១៣៥៥***រូប ក្នុងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម នៅក្រសួងអប់រំ យុវជន និងកីឡា។*

*អនុក្រឹត្យឯកត្តភូត មានចេញចំពោះបុគ្គលចំណោះផ្សេងៗទៀត ក្រៅពីពួកមន្ត្រីរាជការ ដូចជា ការជូនមេដាយស្ថាបនាជាតិជា*

*ដើម ដល់សប្បុរសជនដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ក្នុងវិស័យស្ថាបនាជាតិ*[4]

**២.៣-ប្រកាស**

*ប្រកាស គឺជាលិខិតបទដ្ឋាន ឬសេចក្តីសម្រេចមួយដែលចេញ និងចុះហត្ថលេខាដោយសមាជិករាជរដ្ឋាភិបាលដែលជាប្រធានស្ថាប័ន (រដ្ឋមន្ត្រី) សម្រាប់គ្រប់គ្រង និងដឹកនាំកិច្ចការដែលជាសមត្ថកិច្ច នៃក្រសួង ស្ថាប័នរបស់ខ្លួន។ ប្រកាសរបស់ប្រធានស្ថាប័នត្រូវស្របជាមួយលិខិតបទដ្ឋាននានា ដូចជាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ជាដើម។ ប្រកាសមានទម្រង់ជា៖*

***ក-ប្រកាសបទបញ្ជា៖*** *ច្បាប់បានកំណត់នូវកិច្ចការឬវិស័យណាមួយរបស់ប្រទេសជាតិថាត្រូវធ្វើជាប្រកាសដើម្បីជាលិខិតបទដ្ឋាន(បទបញ្ជា)បន្តសម្រាប់មន្ត្រី ឬប្រជាពលរដ្ឋយកទៅគោរព និងអនុវត្ត។*

***ឧទាហរណ៍៖***

*-ប្រកាសរបស់ក្រសួងមហាផ្ទៃ លេខ ៤២៧៤ ប្រ.ក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ ។*

*-ប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ៣៩ កយ.ប្រក/១០ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០១០ ស្តីពីការបង្កើតមជ្ឈមណ្ឌលសេវាកម្មយុត្តិធម៌ ក្រុង ខណ្ឌ។*

*-ប្រកាសរបស់ក្រសួងមហាផ្ទៃ លេខ ១២៣ ប្រ.ក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ ស្តីពី ការបង្កើត និងបំបែកភូមិ នៃខេត្តកំពង់ចាម។*

*ប្រកាស អាចមានទម្រង់ជាប្រកាសអន្តរក្រសួង ដែលមានចុះហត្ថលេខាដោយរដ្ឋមន្ត្រីច្រើនក្រសួងសម្រាប់ដាក់បញ្ញាដែលពាក់ព័ន្ធដល់កិច្ចការរបស់ក្រសួងហត្ថលេខី។*

***ឧទាហរណ៍៖***

*-ប្រកាសអន្តរក្រសួង លេខ ៤៥៧ សហវ.ប្រក.ចមព ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៧ ស្តីពី កម្រៃរដ្ឋបាលក្នុងការចុះបញ្ជីម៉ាក និងកម្រៃរដ្ឋបាលពាក់ព័ន្ធនានា។*

*-ប្រកាសអន្តរក្រសួង លេខ ១៤១៤ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ២០១៩ ស្តីពីការផ្តល់សេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក។*

*-ប្រកាសអន្តរក្រសួង លេខ ២៥២/២៣ ក.ប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិកប.ស.ស.ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២(ពីរ)ឆ្នាំ។*

***ខ-ប្រកាសឯកត្តភូត៖*** *សម្រាប់តែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចរបស់មន្ត្រី*

[4] *សាយ បូរី៖ នីតិរដ្ឋបាលទូទៅ ជ.ឯ.ម.*

រាជការនៅតាមក្រសួង ស្ថាប័ន អង្គភាពនីមួយៗរបស់រដ្ឋ ឬសម្រាប់អនុញ្ញាត ដកអាជ្ញាប័ណ្ណ និងតែងតាំងគណៈកម្មការផ្សេងៗជាដើម។

រដ្ឋមន្ត្រី(ប្រធានស្ថាប័ន) មានសិទ្ធិចេញប្រកាសតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទ ដូចជា អនុប្រធាននាយដ្ឋាន ប្រធាននិងអនុប្រធានការិយាល័យ (ថ្នាក់កណ្តាល) ព្រឹទ្ធបុរសរង អភិបាលរងក្រុង ស្រុក ខណ្ឌ ប្រធានមន្ទីររាជធានី ខេត្ត នាយករដ្ឋបាលសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ស្មៀនឃុំ សង្កាត់ និងមុខតំណែងផ្សេងៗទៀតដែលមានឋានៈស្មើនឹងមុខតំណែងខាងលើ។

**ឧទាហរណ៍៖**

-ប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ ៣០៧ អយក.ប្រក ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងលោក **ខាត់ សាម៉ាល់** ជាប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី នៃក្រសួងអប់រំ យុវជន និងកីឡា ។

-ប្រកាសរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៩៦ ប្រក.បល. ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងមន្ត្រីរាជការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន **៦៩**រូប ជាអនុប្រធាននាយកដ្ឋាន។

-ប្រកាសរបស់ក្រសួងមហាផ្ទៃ លេខ ៤៦៦២ ប្រ.ក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២ ស្តីពី ការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន **១០**រូប ជា នាយករដ្ឋបាល នៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនានា នៃរាជធានីភ្នំពេញ។

-ប្រកាសរបស់ក្រសួងមហាផ្ទៃ លេខ ៥៤៤៤ ប្រ.ក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២ ស្តីពី ការតែងតាំងមន្ត្រីរាជការចំនួន **២០**រូប ឱ្យកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលក្រុង ស្រុក នៅក្នុងខេត្តតាកែវ។

ឋានន្តរស័ក្តិ ថ្នាក់ វរសេនីយ៍ទោ (ស័ក្តិ៤កន្ទះ)ចុះ អនុមន្ត្រី និងឋានន្តរស័ក្តិទី៣ នៃក្របខណ្ឌប្រភេទ **ក**(ក៣) ក្របខណ្ឌប្រភេទ **ខ** និងក្របខណ្ឌប្រភេទ **គ** ក៏ត្រូវដំឡើងដោយប្រកាសផងដែរ។

**ឧទាហរណ៍៖**

-ប្រកាសរបស់ក្រសួងមុខងារសាធារណៈ លេខ ១៦៦១/២២ មស.ប្រក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ ស្តីពី ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់តាមកម្រិតសញ្ញាបត្រ ជូនមន្ត្រីរាជការចំនួន**១៩**នាក់ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្របខ័ណ្ឌមន្ត្រីក្រមការ និងក្របខ័ណ្ឌលេខាធិការរដ្ឋបាល នៅក្រសួងទេសចរណ៍។

-ប្រកាសរបស់ក្រសួងមុខងារសាធារណៈ លេខ ១៣០៩/២៣ មស.ប្រក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ ស្តីពី ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិប្រចាំឆ្នាំ២០២៣ ជូនមន្ត្រីរាជការចំនួន **២៣៩**នាក់ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្របខ័ណ្ឌមន្ត្រីក្រមការ និង

*ក្របខ័ណ្ឌលេខាធិការរដ្ឋបាល របស់ទីស្ដីការគណៈរដ្ឋមន្ត្រី។*

*-ប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ ១០១០ អយក.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣ ស្ដីពី ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ជូនបុគ្គលិកអប់រំចំនួន **១៩៤៤០** នាក់ នៃក្រសួងអប់រំ យុវជន និងកីឡា ។*

## ២.៤-សេចក្ដីសម្រេច

*សេចក្ដីសម្រេច មានពីរ គឺសេចក្ដីសម្រេចរបស់នាយករដ្ឋមន្ត្រី និងសេចក្ដីសម្រេចរបស់ប្រធានស្ថាប័ន។*

***ក-សេចក្ដីសម្រេចរបស់នាយករដ្ឋមន្ត្រី៖*** *រាជរដ្ឋាភិបាលអាចចេញសេចក្ដីសម្រេចដែលមានលក្ខណៈជាបទបញ្ញាឬឯកត្តកូតដោយយកទម្រង់សាមញ្ញជា "**សេចក្ដីសម្រេច**"។ "សេចក្ដីសម្រេច" ជាធម្មតាច្រើននៅក្រោមអនុក្រឹត្យដើម្បីអនុវត្តក្នុងកិច្ចការរដ្ឋបាលលម្អិតបន្តទៅទៀត ហើយពុំអាចមានខ្លឹមសារផ្ទុយពីអនុក្រឹត្យបានឡើយ។*

***ឧទាហរណ៍៖***

*-សេចក្ដីសម្រេចលេខ ៦១ សសរ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពី ការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចថ្នាក់ដឹកនាំរាជរដ្ឋាភិបាល។*

*-សេចក្ដីសម្រេចលេខ ៩៨ សសរ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពី ការតែងតាំងសមាសភាពអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។*

*-សេចក្ដីសម្រេចលេខ ១៦១ សសរ ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពី ការតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួងពិនិត្យនិងវាយតម្លៃលើសំណើសុំគោរមងារនិងការបញ្ចប់គោរមងារឧកញ៉ា។*

***ខ-សេចក្ដីសម្រេចរបស់ប្រធានស្ថាប័ន៖*** *ប្រធានស្ថាប័ន ដែលជារដ្ឋមន្ត្រីនៃក្រសួងស្ថាប័ននីមួយៗ ច្រើនធ្វើសេចក្ដីសម្រេចតាមទម្រង់ជា "**ប្រកាស**" ប៉ុន្តែក៏អាចចេញបទបញ្ញាដែលមានទម្រង់ ជា "**សេចក្ដីសម្រេច**" បានដែរ ហើយមិនអាចមានខ្លឹមសារផ្ទុយ ឬខុសនឹងខ្លឹមសាររបស់លិខិតបទដ្ឋានថ្នាក់លើ ដូចជាសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល អនុក្រឹត្យ ព្រះរាជក្រឹត្យ ព្រះរាជក្រមបានឡើយ។*

***ឧទាហរណ៍៖***

*-សេចក្ដីសម្រេចលេខ ២០ សសរ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣ ស្ដីពី ការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចថ្នាក់ដឹកនាំទីស្ដីការគណៈរដ្ឋមន្ត្រី។*

*-សេចក្ដីសម្រេចលេខ ៤៦៨៦ សសរ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពី ការផ្អាកសកម្មភាព ស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបផលិតផលក្លែងក្លាយ ស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ។*

*-សេចក្ដីសម្រេចលេខ ០២០៥ ផក ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពី ការបង្កើតក្រុមការងារព័ត៌មាននិងបណ្ដាញទំនាក់ទំនងសង្គមរបស់ក្រសួងផែនការ។*

**២.៥-សារាចរ/សារាចរណែនាំ**

*សារាចរ គឺជាអត្ថបទសម្រាប់បំភ្លឺកិច្ចការ និងធ្វើការណែនាំ។ សារាចរ មានគោលដៅបំភ្លឺចំណុចខ្វះនៃអត្ថបទច្បាប់ ឬបទបញ្ញាដូចជា ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដែលរាជរដ្ឋាភិបាល ឬប្រធាន ស្ថាប័នចង់ឱ្យមានការយល់ច្បាស់ និងឱ្យមានការអនុវត្តដូចៗគ្នាដោយភ្នាក់ងារសាធារណៈដែលស្ថិតនៅក្រោមបង្គាប់របស់រាជរដ្ឋាភិបាល ឬក្រសួងស្ថាប័ន។ សារាចររបស់រាជរដ្ឋាភិបាល មានឋានៈខ្ពស់ជាងសារាចររបស់ស្ថាប័ន ហើយសារាចររបស់ស្ថាប័នត្រូវតែស្របជានិច្ចជាមួយនឹងសារាចររបស់រាជរដ្ឋាភិបាល។*

***ឧទាហរណ៍៖***

*-សារាចររបស់រាជរដ្ឋាភិបាលលេខ៨ សរ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ ស្តីពី ការទប់ស្កាត់ការវាយកម្ទេចនិងបំផ្លិចបំផ្លាញសំណង់អគារបេតិកភណ្ឌ។*

*-សារាចររបស់ក្រសួងទេសចរណ៍ លេខ ០០៤ សរច ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ ស្តីពី ការប្រើប្រាស់ប្រព័ន្ធបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍។*

*-សារាចរណែនាំរបស់ក្រសួងធម្មការ និង សាសនា លេខ ១៩/២៣ ក.ធ.ស. សរណន ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពី ការអនុវត្តគោលការណ៍ប្រណិប័តន៍លើជំនឿ សាសនា និងប្រពៃណីទំនៀមទម្លាប់ខ្មែរ។*

**២.៦-ដីកា**

*ដីកា គឺជាសេចក្តីសម្រេចរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ ដីកា របស់ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវនៅក្រោមប្រកាស និងលិខិតបទដ្ឋានថ្នាក់លើនានាដូចជា អនុក្រឹត្យ ព្រះរាជក្រឹត្យ ជាដើម។*

***ឧទាហរណ៍៖***

*-ដីការបស់សាលាខេត្តកណ្តាល លេខ ០៤៤ ដ.ក ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៦ ស្តីពីការកែសម្រួល សមាសភាពគណៈបញ្ជាការឯកភាពខេត្តកណ្តាល។*

*-ដីការបស់រដ្ឋបាលខេត្តតាកែវ លេខ ០៦៤/២៣ ដក.តត ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងលោក* ***នុត មូរ៉ា*** *អត្តលេខ ១៨២២១០០៣៧៥ ឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេសថ្នាក់លេខ៥ ឱ្យកាន់មុខតំណែងជា អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ។*

*-ដីការបស់រដ្ឋបាលខណ្ឌច្បារអំពៅ លេខ ០០៣/២៣ ដក.ចអព.អណ៣ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី ការលើកលែងការបង់តម្លៃសេវាលើការបញ្ជាក់វិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ វិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាទុតិយភូមិ និងវិញ្ញាបនបត្រ*

បញ្ជាក់កាសិក្សាថ្នាក់ទី១២ សម្រាប់ឆ្នាំ ២០២៣។

យើងសង្កេតឃើញថា លិខិតបទដ្ឋាន គតិយុត្តខាងលើនេះ នៅត្រង់មាត្រា ប្រការ ឬវាក្យខណ្ឌ ចុងក្រោយគេតែងដាក់ថា "អនុវត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខា ឬចុះហត្ថលេខាតទៅ"។

# ឯកសារពិគ្រោះ

*១-ជួន ណាត៖ វចនានុក្រមខ្មែរ ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧*

*២-ព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២២៥០ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ស្ដីពីគោរមងារឧកញ៉ា*

*៣-លិខិតបទដ្ឋានគតិយុត្តសម្រាប់គាំទ្រដល់ដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០០១*

*៤-សាយ បូរី៖ នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៣ ភ្នំពេញ ២០០២*

*៥-ហួត វុទ្ធី៖ ប្រជុំរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ១៩៤៧-២០០៧*

*៦-ហែម ឡាច៖ ស្ថាប័ននយោបាលកម្ពុជាបច្ចុប្បន្ន ឆ្នាំ២០២៣*

*៧-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣*